ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ: ០៨៣/១៣ រ.ប.ក អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៣

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ សីហា ឆ្នាំ២០១៣ និងទិសដៅការងារ ខែ កញ្ញា ឆ្នាំ២០១៣

(ពីថ្ងៃទី ០១/០៨/២០១៣ ដល់ ថ្ងៃទី ៣០/០៨/២០១៣)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្ត្រពហុវិស័យ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានអនុវត្តនៅក្នុង**ខែសីហា ឆ្នាំ២០១៣** នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន និង រាជធានី-ខេត្តចំនួន ១៥ គឺ រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, តាកែវ, កំពង់ឆ្នាំង, កំពង់ចាម, សៀមរាប, ស្ទឹងត្រែង, ព្រះវិហារ, ខេត្តរតនគិរី, បាត់ដំបង, បន្ទាយមានជ័យ, កំពង់ធំ, ក្រចេះ និង ប៉ៃលិន ដែលបានរាយការណ៍ពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរចែកចាយ និងប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបក្នុងខែសីហានេះ កត់សំគាល់ឃើញមានបទល្មើសដឹកជញ្ជូនគ្រឿងញៀនឆ្លងដែន ចំនួន ៤ ករណី គឺ :

- ករណីមេតំហ្វេតាមីន ICE មាន ២ ករណី ក្នុងនោះ ១ករណីត្រូវបានបណ្តាញនៃក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិ ដែលជាស្ត្រីជនជាតិថៃ នាំពីប្រទេសឥណ្ឌាឆ្លងកាត់តាមច្រកអាកាសយានដ្ឋានក្រុងកូឡាឡំពួរ ប្រទេសម៉ាឡេស៊ី មកចុះនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញតាមជើងយន្តហោះលេខ MH 754 និង១ករណីទៀតនាំមកពីប្រទេសកាតា ដោយស្ត្រីជនជាតិនីហ្សេរីយ៉ា មកចុះនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញតាមជើងយន្តហោះRQ604 ដូហា-ភ្នំពេញ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone , Fax: (855) 23 721 648, Fax: (855) 23 727 529
E-mail: info@nacd.gov.kh, Website: www.nacd.gov.kh

- ករណី កូកាអ៊ីន មាន ២ ករណី ។ ១ករណីធ្វើសកម្មភាពដឹកជញ្ជូនដោយបណ្តាញក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិដែលជាស្ត្រីជនជាតិឥណ្ឌូនេស៊ី បាននាំពីប្រទេសហ្វីលីពីន់តាមច្រកអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប និង១ករណីទៀតធ្វើសកម្មភាពដោយបុរសជនជាតិរ៉ូម៉ានី បាននាំពីប្រទេសប្រេស៊ីលហើយបន្តដំណើរតាមជើងយន្តហោះពីប្រទេសសឹង្ហបុរីមកចុះនៅអាកាសយានដ្ឋានខេត្តសៀមរាប ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### *អំពីការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន :

- បានណែនាំឱ្យជំរុញកិច្ចសហការជាមួយមន្ត្រីជំនាញផ្នែកព័ត៌មានវិទ្យារបស់ក្រសួងផែនការ លើការប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន សម្រាប់ការដៅចំណុចគោលដៅឃុំ-សង្កាត់ ស្រុក-ខណ្ឌ ពាក់ព័ន្ធបញ្ហាគ្រឿងញៀននៅលើផែនទី ។
- បានណែនាំឱ្យរៀបចំផ្សព្វផ្សាយជាផ្លូវការនូវទិន្នន័យនៃការប៉ាន់ប្រមាណពីចំនួនអ្នកប្រើប៉ាន់គ្រឿងញៀននៅកម្ពុជា ។
- បានណែនាំឱ្យបន្តការពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិរបស់អាជ្ញាធរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- បានណែនាំឱ្យបន្តត្រួតពិនិត្យការអនុវត្តផែនការជាតិ៣ឆ្នាំ (២០១៣-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ទន្ទឹមនេះ ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ក៏ដូចជាផែនការអនុវត្តន៍ទិសដៅការងារ ដែលបានដាក់ចេញកាលពីខែកក្កដាឆ្នាំ២០១៣កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តវិធានការពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

### *ក. ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួង-ស្ថាប័ន ជាសមាជិក និងក្រសួង-ស្ថាប័នមួយចំនួនទៀត ជាអាទិ៍ អគ្គិសនីកម្ពុជា បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយតាមកម្មវិធីប្រចាំថ្ងៃ-សប្តាហ៍-ខែ, ការអប់រំតាមសហគមន៍, ការបណ្តុះបណ្តាលធនធានមនុស្ស ទទួលបានលទ្ធផលគួរកត់សំគាល់ ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១ ។ **ដោយឡែក :**

**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :**

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមជាវាគ្មិននៅក្នុងសិក្ខាសាលារបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ដើម្បីផ្សព្វផ្សាយអប់រំពីសភាពការណ៍គ្រឿងញៀន ឥទ្ធិពល ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់សាស្ត្រាចារ្យ និង និស្សិតចំនួន <u>៣០០</u> នាក់ ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ និងការងារបណ្តុះបណ្តាលធនធានជនបង្គោល ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ជាសមាជិក អ.ជ.ប.គ.ញ ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន *៨* គឺ ខេត្តរតនគិរី, កំពង់ធំ, កែប, ស្វាយរៀង, បាត់ដំបង, តាកែវ, ក្រចេះ, ព្រះវិហារ នៅក្នុងខែសីហា ឆ្នាំ២០១៣ នេះ មានមហាជនចូលរួមសរុប ***៧៩.៥៦៩ នាក់*** លើ

២៣.៥៩៣ នាក់ នៃខែកក្កដា ដូចមានទៅក្នុងតារាងឧបសម្ព័ន្ធទី១ ។

## ខ. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

ខែសីហាឆ្នាំ២០១៣នេះ មន្ត្រីអនុវត្តន៍ច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

### ខ.១. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៤៤** ករណី លើ ៥២ ករណី នៃខែកក្កដា ឆ្នាំ២០១៣
- **ជនសង្ស័យ** ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ឃាត់ខ្លួន **១០៥** នាក់ លើ ១១៧ នាក់ នៃខែកក្កដា ឆ្នាំ២០១៣

ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានឃាត់ខ្លួនទាំង **១០៥** នាក់ ខាងលើ មានប្រុស ៨០ នាក់ ស្រី ២៥ នាក់ ក្នុងនោះ ជនជាតិ **ខ្មែរ** ៩៦ នាក់ (ស្រី ២០ នាក់), **វៀតណាម** ៣ នាក់ (ស្រី ២ នាក់), **ថៃ ១** នាក់ (ស្រី), **ឥណ្ឌូនេស៊ី** ១ នាក់ (ស្រី), **ចិន** ៣ នាក់ (ប្រុស), **នីហ្សេរីយ៉ា** ១ នាក់ (ស្រី) ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

- **វត្ថុតាងគ្រឿងញៀន ចាប់យក** រួមមាន : មេតំហ្វេតាមីន WY ១៩,៦៦ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ Ice ៧.២៣១,៥២ ក្រាម, កូកាអ៊ីន ២,៤៩០ ក្រាម ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ចាប់យក** រួមមាន : ម៉ូតូ ១៤ គ្រឿង, ប្រាក់កម្ពុជា ១.៩៦៤.៨០០ រៀល, ប្រាក់អាមេរិក ១១៧ ដុល្លារ **ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២** ។

**ដោយឡែក :**

- **ជនសង្ស័យ ចាប់តាមដីកា មាន** ២ ដីកា = មនុស្ស ២ នាក់ (ប្រុស) ជនជាតិខ្មែរ ១ នាក់, អាមេរិក ១ នាក់ ក៏ត្រូវបានបញ្ជូនខ្លួនទៅសាលាដំបូងរាជធានី-ខេត្តសាមីផងដែរ ។

### ខ.២. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលនៅក្នុងខែ**សីហា** ឆ្នាំ២០១៣ មានដូចខាងក្រោម :

- សារធាតុគីមី ចំនួន ៧.៣៩៤.០៦៤ គីឡូក្រាម ១ លីត្រ ៨០ អំពូល និង ៤២ ដប ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២ ។

### ខ.៣. ការងារកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តច្បាប់នានា នៅក្នុងខែសីហានេះ សរុបបានចំនួន ៤២ ករណី = ៤៨ សំណាក (**សំណាកអវិជ្ជមានសារធាតុញៀន** ១ សំណាក = ១ % និង សំណាក**វិជ្ជមានសារធាតុញៀន** ៤៧ សំណាក = ៩៩ %) ក្នុងនោះគឺ ៖

-មេតំហ្វេតាមីនក្រាមម្សៅ ៤៣ សំណាក = ៩៥ % -មេតំហ្វេតាមីនគ្រាប់ ២ សំណាក = ២ %

-ហេរ៉ូអ៊ីន ១ សំណាក = ១ % -កញ្ឆា ១ សំណាក = ១ %

**ក្រៅពីការងារខាងលើ** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានទទួលនូវតេស្តសម្រាប់រកសារធាតុញៀនក្នុងទឹកនោម ចំនួន ២.០០០ តេស្ត ក្នុងនោះ : តេស្តសម្រាប់រកសារធាតុមេតំហ្វេតាមីនក្នុងទឹកនោម ចំនួន ១.០០០ តេស្ត និង តេស្តសម្រាប់រកសារធាតុឈ្មោះ អឹម.ដេ.អឹម.អា (ហៅអ៊ិចស្តាស៊ី) កូកាអ៊ីន និង បង់ហ្សូឌីយ៉ាហ្សេពីន ក្នុងទឹកនោម ចំនួន ១.០០០ តេស្ត ពីក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៣ ។

## គ. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់ទីជំរកវិជ្ជាជីវៈ និងសមាហរណកម្ម

### គ.១. កម្មវិធីកាត់បន្ថយគ្រោះថ្នាក់

**ការងារក្នុងប្រទេស**

- បានចូលរួមតាមការអញ្ជើញរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ដើម្បីពិភាក្សាចែករំលែកបទពិសោធន៍ និងព័ត៌មានសំខាន់ៗ ព្រមទាំងជជែកពិភាក្សាស្វែងរកយុទ្ធសាស្ត្រ ជំរុញគោលនយោបាយគ្រឿងស្រវឹងសំដៅកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង (ដែលអាចពាក់ព័ន្ធដល់ការប្រើបំពានគ្រឿងញៀន) ថ្ងៃទី០៩/០៨/២០១៣ ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ លើកទី២ (២២/០៨/២០១៣) លើសេចក្តីព្រាងប្រកាសស្តីពី "លក្ខខណ្ឌការងារ និងវិធានអនាម័យ សន្តិសុខការងារ នៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ផ្នែកសេវាកម្សាន្ត" តាមការអញ្ជើញរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ នៅក្នុងកិច្ចប្រជុំនេះ តំណាងរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានស្នើសុំដាក់បញ្ចូលនូវខ្លឹមសារអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ទៅក្នុង "ប្រការ៩" នៃប្រកាស ។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងយកសំណើនេះ ស្នើសុំការសម្រេចពីរដ្ឋមន្ត្រី ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ១រូប ទៅចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីផែនទីបង្ហាញផ្លូវ សម្រាប់បង្កើតផែនការជាតិអភិវឌ្ឍន៍កុមារ រយៈពេល១០ឆ្នាំ (២០១៥-២០២៥) តាមការអញ្ជើញរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន ។ ក្នុងសិក្ខាសាលានេះ តំណាងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសំណូមពរបញ្ចូលបញ្ហាកុមារនិងគ្រឿងញៀន និងមន្ត្រីបច្ចេកទេសពី អ.ជ.ប.គ.ញ ទៅក្នុងក្រុមការងាររបស់ក្រុមប្រឹក្សាជាតិដើម្បីកុមារ ។ សំណូមពរនេះត្រូវបានយកទៅស្នើសុំការសម្រេចពីរដ្ឋមន្ត្រី ។

**ការងារក្រៅប្រទេស**

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ចំនួន ០២ រូប ទៅចូលរួមក្នុងសិក្ខាសាលាស្តីពីកម្មវិធី Global Smart ថ្នាក់តំបន់សម្រាប់អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ នៅប្រទេសឥណ្ឌូនេស៊ី ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងសម្របសម្រួលជូនមន្ត្រីនគរបាលជាន់ខ្ពស់ ទៅទទួលការបណ្តុះបណ្តាលដើម្បីពង្រឹងប្រសិទ្ធភាពការងារពាក់ព័ន្ធនឹងការអនុវត្តគម្រោង HAARP នៅកម្ពុជា នៅទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី ។

- ***គ.២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម***

**ការងារក្នុងប្រទេស**

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានរៀបចំកិច្ចប្រជុំពិភាក្សាអំពីការផ្តល់ជំនួយជាវគ្គបណ្តុះបណ្តាល និងសម្ភារៈ ឱសថ សម្រាប់មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលត្រូវផ្តល់ដោយភាគីវៀតណាម ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញចូលរួមក្នុងវគ្គបណ្តុះបណ្តាលនៅខេត្តសៀមរាប (០៦-០៩/៨/២០១៣ អ្នកចូលរួម **២៥** នាក់) និងនៅខេត្តបាត់ដំបង (១២-១៤/៨/២០១៣ អ្នកចូលរួម **៣៥** នាក់) ពាក់ព័ន្ធនឹងកម្មវិធីបង្ការមេរោគអេដស៍ និងគ្រឿងញៀន ក្នុងចំណោមស្ត្រីធ្វើការតាមសេវាកម្សាន្តនៅប្រទេសកម្ពុជា (CIPI) ។

## ***ឃ. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់***

**ការងារក្នុងប្រទេស**

- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងសម្របសម្រួលជូនមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO) ច្រកចាំយាម ច្រកព្រំ ច្រកដូង និង ច្រកប៉ោយប៉ែត ទៅចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងទៅនឹងការរត់ពន្ធខុសច្បាប់ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។
- បានសហការជាមួយសាលាបណ្ឌិត្យសភានគរបាលកម្ពុជា បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល លើកទី២ ចំនួន **៣៩** រូប ស្តីពីកម្មវិធីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើបំពានគ្រឿងញៀន សម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ។

**ដោយឡែក** ខេត្តបន្ទាយមានជ័យ ថ្ងៃទី២២/៨/២០១៣ បានបើកកិច្ចប្រជុំសមត្ថកិច្ចចម្រុះ (ក្នុងក្របខណ្ឌថ្នាក់ខេត្ត) នៅក្រុងប៉ោយប៉ែត ដើម្បីរិះរកវិធានការទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ (រួមទាំងបទល្មើសគ្រឿងញៀន) ។

**ការងារក្រៅប្រទេស**

- បានសម្របសម្រួលជូនមន្ត្រីនៃស្ថាប័នអនុវត្ត រួមមាន នគរបាល កងរាជអាវុធហត្ថ គយនិងរដ្ឋាករ និងមន្ត្រី នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សរុបចំនួន ៣០ រូប ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពីការងារត្រួតពិនិត្យគ្រឿងញៀន នៅសាលាបណ្ឌិត្យសភានគរបាលខេត្តយូណាន់ សាធារណរដ្ឋប្រជាមានិតចិន ។

## ***ង. កិច្ចសហប្រតិបត្តិការអន្តរជាតិ***

ខែសីហាឆ្នាំ២០១៣នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាង ក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ មានដូចខាងក្រោម :

**ការងារក្នុងប្រទេស**

- បានបំពេញសំណួរសម្រាប់ការវាយតម្លៃថ្នាក់ជាតិរបស់កម្ពុជា នៃការអនុវត្តផែនការលំអិត ASCC និងចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលរបស់ក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌ អាស៊ាន ដើម្បីវិភាគការសម្រេចបានគោលដៅ និងបញ្ហាប្រឈមផ្សេងៗក្នុងការអនុវត្តផែនការលំអិតASCC ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៥/៧/២០១៣

នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

- បានបំពេញកម្រងសំណួរ តាមការស្នើសុំរបស់ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ដើម្បីរៀបចំគម្រោងស្រាវជ្រាវ ស្តីពីការធ្វើឱ្យមានប្រសិទ្ធភាពកើនឡើងក្នុងការអនុវត្តច្បាប់លើករណីគ្រឿងញៀន និងច្បាប់រឹបអូស ។
- បានរៀបចំទទួលគណៈប្រតិភូការិយាល័យត្រួតពិនិត្យគ្រឿងញៀនភូមិភាគ២ (ថៃ) ដែលអញ្ជើញមកទស្សនកិច្ចសិក្សានៅកម្ពុជា ពីថ្ងៃទី១៧-២៣/៨/២០១៣ ដែលមានគោលបំណងសំខាន់ ដើម្បីជួបជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តប៉ៃលិន បាត់ដំបង និងបន្ទាយមានជ័យ ពាក់ព័ន្ធនឹងការងារត្រួតពិនិត្យគ្រឿងញៀន ។

**ការងារក្រៅប្រទេស**

- បានចាត់តាំងថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប និងសម្របសម្រួលជូនមន្ត្រីស្ថាប័នអនុវត្តច្បាប់ពាក់ព័ន្ធ ១ រូប ទៅចូលរួមសិក្ខាសាលាស្តីពី កិច្ចសហប្រតិបត្តិការសម្រាប់ប្រទេសអាស៊ីបូព៌ានិងអាមេរិកឡាទីន កាលពីថ្ងៃទី២៩ ខែកក្កដា ដល់ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ ក្នុងគោលបំណង :
  ១. ពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធ និងចូលរួមប្រតិបត្តិការរួមគ្នា លើការងារបង្ក្រាបគ្រឿងញៀននាពេលអនាគតរបស់ប្រទេសជាសមាជិក FEALAC ។
  ២. ផ្លាស់ប្តូរព័ត៌មានឱ្យបានទៀងទាត់ (៤ខែម្តង) នូវរបាយការណ៍ស្តីពីបច្ចុប្បន្នភាពស្ថានភាពគ្រឿងញៀន របស់រដ្ឋជាសមាជិកនីមួយៗ តាមរយៈសារអេឡិចត្រូនិច ។
- ចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ទៅចូលរួមសិក្ខាសាលាមន្ត្រីសម្របសម្រួលគម្រោង PARTOL កាលពីថ្ងៃទី២៦-២៧/៨/២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ ។ **ដោយឡែក :**

**ខេត្តបន្ទាយមានជ័យ**

- ថ្ងៃទី២៥/៧/២០១៣ មន្ត្រីអនុវត្តច្បាប់គ្រប់ប្រភេទនៅក្រុងប៉ោយប៉ែត មានសមាសភាពចំនួន ១៨ នាក់ បានជួបប្រជុំពិភាក្សាការងារ ជាមួយអាជ្ញាធរស្រុកអរញ្ញ ខេត្តស្រះកែវ (ធ្វើនៅក្រុងប៉ោយប៉ែត) ដើម្បីដោះស្រាយបញ្ហាប្រឈម និងរកវិធីទប់ស្កាត់បទល្មើសដែលកើតមាននៅតាមខ្សែបន្ទាត់ព្រំដែន ជាអាទិ៍ ១). ការទប់ស្កាត់បទល្មើសគ្រឿងញៀន ២). ការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសជនសង្ស័យលួចចូលមកលាក់ខ្លួន និង ៣). ការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់ ។
- ថ្ងៃទី១៩/៨/២០១៣ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត បានជួបពិភាក្សាការងារជាមួយការិយាល័យត្រួតពិនិត្យគ្រឿងញៀន ភូមិភាគ២ (ថៃ) ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀននៅបន្ទាត់ព្រំដែន កម្ពុជា-ថៃ ។
- ថ្ងៃទី២២/៨/២០១៣ បានបើកកិច្ចប្រជុំសមត្ថកិច្ចចម្រុះ (ក្នុងក្របខណ្ឌថ្នាក់ខេត្ត) នៅក្រុងប៉ោយប៉ែត ដើម្បីរិះរកវិធានការទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ (រួមទាំងបទល្មើសគ្រឿងញៀន) ។

**ខេត្តបាត់ដំបង**

- ថ្ងៃទី២២/៨/២០១៣ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត បានជួបពិភាក្សាការងារជាមួយការិយាល័យត្រួតពិនិត្យគ្រឿងញៀន ភូមិភាគ២ (ថៃ) ពាក់ព័ន្ធនឹងការងារត្រួតពិនិត្យគ្រឿងញៀន នៅខេត្តបាត់ដំបង ។

**ខេត្តប៉ៃលិន**

- ថ្ងៃទី២២/៨/២០១៣ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត បានជួបពិភាក្សាការងារជាមួយការិយាល័យត្រួតពិនិត្យគ្រឿងញៀន ភូមិភាគ២ (ថៃ) ពាក់ព័ន្ធនឹងការងារត្រួតពិនិត្យគ្រឿងញៀន នៅខេត្តប៉ៃលិន ។

***ការងារផ្សេងៗ :***

- បាននិងកំពុងបន្តការរៀបចំក្រុមបាឋកថា សម្រាប់បម្រើឱ្យការងារផ្សព្វផ្សាយច្បាប់ និងការងារផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។
- បានបន្តពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិរបស់អាជ្ញាធរជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែកញ្ញា ឆ្នាំ២០១៣

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. ស្នើសុំទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រះសីហនុ ដើម្បីផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធី សភាអ៊ីនធឺណែត នៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី អំពីសកម្មភាព និងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀននៅក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ (ថ្ងៃទី២៩ខែកញ្ញាឆ្នាំ២០១៣) ។

១.២. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បណ្តាក្រុមហ៊ុនឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្ម នៅតាមរាជធានី-ខេត្ត និងនៅតាមវិទ្យាល័យក្នុងរាជធានីភ្នំពេញ ។

១.៣. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន ។

### ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. សហការសម្របសម្រួលជាមួយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បី :

- រៀបចំសៀវភៅបញ្ជីគ្រប់គ្រងសារធាតុគីមី ដូចក្នុងតារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- រៀបចំស្លាកសញ្ញាសារធាតុគីមីជាភាសាខ្មែរ សម្រាប់បិទលើសំបកវេចខ្ចប់ ។
- ជំរុញឱ្យម្ចាស់រោងចក្រ សិប្បកម្ម បិទពាក្យស្លោកអប់រំពីបញ្ហាគ្រឿងញៀន នៅលើផលិតផលរបស់ខ្លួន ។
- រៀបចំ Help Desk ដើម្បីផ្តល់ប្រឹក្សាដល់វិស័យឯកជន និងគ្រប់ភាគីពាក់ព័ន្ធ ។
- រៀបចំវគ្គបណ្តុះបណ្តាលដល់វិស័យឯកជនរួមទាំងកម្មករ អំពីការទុកដាក់ ការប្រើប្រាស់សារធាតុគីមី និងសារធាតុគ្រោះថ្នាក់ នៅតាមរោងចក្រ សិប្បកម្ម និង ក្រុមហ៊ុន ។

២.២. សហការជាមួយអង្គការ UNODC ដើម្បីដំណើរការវិភាគឱ្យបានច្បាស់លាស់ពីរុក្ខជាតិវល្លិ៍រមៀត ដែលសង្ស័យថាមានផ្ទុកសារធាតុផ្សំសម្រាប់ផលិតគ្រឿងញៀនខុសច្បាប់ ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. ត្រៀមចាត់មន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន ២ រូប ទៅចូលរួមសិក្ខាសាលាអាស៊ានស្តីពី ការបង្ការការប្រើបំពានគ្រឿងញៀន ដោយផ្អែកលើសហគមន៍ (នៅប្រទេសហ្វីលីពីន ថ្ងៃទី០២-០៦/៩/២០១៣) ។

៣.២. ត្រៀមចាត់មន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ និងសម្របសម្រួលជូនមន្ត្រីមជ្ឈមណ្ឌលព្យាបាលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន របស់រាជធានី-ខេត្តពាក់ព័ន្ធ ទៅទទួលវគ្គបណ្តុះបណ្តាលគំរូ លើកទី៥ ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀន (នៅប្រទេសថៃ ថ្ងៃទី០៩-២០/៩/២០១៣) ។

៣.៣. រៀបចំគម្រោងសម្រាប់ការបណ្តុះបណ្តាលពាក់ព័ន្ធផ្នែកព្យាបាល និង ផ្នែកស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគម្រោងតម្រូវការសម្ភារៈ ឱសថ ដែលត្រូវផ្តល់ដោយភាគីវៀតណាម ។

៣.៤. ត្រៀមបញ្ជូនក្រុមការងារអន្តរក្រសួង ទៅប្រទេសវៀតណាម ដើម្បីពិភាក្សាពីជំនួយរបស់ភាគីវៀតណាម ពាក់ព័ន្ធនឹងការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៣.៥. សហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំឯកសារដែលពាក់ព័ន្ធនឹងការបង្ការ ការថែទាំ និងព្យាបាលបន្ត និង ស្តារនីតិសម្បទាចិត្ត-សង្គម ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ។

៣.៦. រៀបចំយន្តការ និងបែបបទសម្រាប់ការអនុវត្តកម្មវិធី ម្ទុល/សឺរ៉ាំង តាមប្រព័ន្ធសុខាភិបាល ។

៣.៧. បន្តការផ្តល់សេវាថែទាំ ព្យាបាល និងផ្តល់របបឧបត្ថម្ភដល់អ្នកញៀនគ្រឿងញៀន ដែលកំពុងសម្រាកព្យាបាលនៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ។

៣.៨. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ជំរុញការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

៣.៩. បន្តរៀបចំឯកសារគោលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៣.១០. សហការជាមួយការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម (UNODC) រៀបចំផ្សព្វផ្សាយកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ជាមូលដ្ឋាន ឆ្នាំ២០១២ នៅខេត្តបន្ទាយមានជ័យ (CBTx) ដែលបានធ្វើបច្ចុប្បន្នភាពរួចហើយ ។

៣.១១. ជួបពិភាក្សាជាមួយតំណាងអង្គការសុខភាពពិភពលោក (WHO) ដើម្បីស្វែងយល់អំពីស្ថានភាពអ្នកប្រើគ្រឿងញៀន និងការឆ្លងមេរោគអេដស៍ ដោយការចាក់គ្រឿងញៀនតាម ម្ទុល / សឺរ៉ាំង នៅកម្ពុជា ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៤.២. បន្តកិច្ចសហការជាមួយអង្គការFHI360 រៀបចំរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនឱ្យបានច្បាស់លាស់ និងជ្រើសរើសមន្ត្រីជំនាញផ្នែកព័ត៌មានវិទ្យា (I.T) បន្ថែមសម្រាប់បម្រើការងារប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន ។

៤.៣. ត្រៀមកិច្ចសហការសម្របសម្រួលជាមួយក្រសួងការពារជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់កងយោធពល

ខេមរភូមិន្ទ ពិសេសកងទ័ពឈរជើងនៅតាមខ្សែបន្ទាត់ព្រំដែននៃបណ្តាខេត្តនៅភាគឦសាន ។

៤.៤. បន្តរៀបចំវគ្គបណ្តុះបណ្តាល ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ (កម្មវិធី CBT) ។

៤.៥. រៀបចំកិច្ចប្រជុំតុមូលជាមួយអង្គការ FHI360 ដើម្បីពិភាក្សាបន្តលើកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៤.៦. បន្តរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលរបស់សាលាបណ្ឌិត្យសភានគរបាលកម្ពុជា ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ (គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន) ។

៤.៧. បន្តពិនិត្យលើសេចក្តីព្រាង " នីតិវិធីនៃកិច្ចសហប្រតិបត្តិការសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ថៃ " ដែលព្រាងដោយការិយាល័យក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ។

៤.៨. បន្តរៀបចំនិងដាក់បញ្ចូលនូវរាល់សំណើទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម លើកទី១៣ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ដែលក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា នឹងរៀបចំធ្វើនៅខេត្តព្រះសីហនុ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.២. ត្រៀមចូលរួមកិច្ចប្រជុំពិសេសថ្នាក់រដ្ឋមន្ត្រីប្រទេសអាស៊ាន (០២-០៣/៩/២០១៣) នៅប្រទេសប្រ៊ុយណេ ។

៥.៣. រៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និង ខេត្តបន្ទាយមានជ័យ ចំនួន ១០ រូប ទៅបំពេញទស្សនកិច្ចសិក្សា នៅខេត្តយូណាន ប្រទេសចិន (០៩-១៣/៩/២០១៣) ។

៥.៤. ត្រៀមចាត់បញ្ជូនមន្ត្រីចំនួន ៦ រូប របស់ស្ថាប័នពាក់ព័ន្ធទៅទទួលវគ្គបណ្តុះបណ្តាលជំនាញផ្នែកព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅមន្ទីរពេទ្យថាន់យ៉ារ៉ាក់ ប្រទេសថៃ ពីថ្ងៃទី០៩-២០/៩/២០១៣ ។

៥.៥. ត្រៀមចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធ ទៅចូលរួមទស្សនកិច្ចសិក្សាស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមអាកាសយានដ្ឋាន (ថ្ងៃទី២៣-២៧/៩/២០១៣ នៅប្រទេសហ្វីលីពីន) ។

៥.៦. រៀបចំជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងសម្របសម្រួលជូនមន្ត្រីនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីបញ្ហាគ្រឿងញៀន(ASOD) លើកទី៣៤ (២៤-២៧/៩/២០១៣ នៅសហភាពមីយ៉ាន់ម៉ា) ។

៥.៧. ត្រៀមទទួលគណៈប្រតិភូថៃដែលត្រូវមកកម្ពុជា ដើម្បីធ្វើការវាយតម្លៃអំពីសមត្ថភាពមន្ត្រីកម្ពុជាពាក់ព័ន្ធនឹងការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (ថ្ងៃទី២៣-២៦/៩/២០១៣) ។

៥.៨. ត្រៀមរៀបចំពិធីទទួលសម្ភារៈ ដែលឧបត្ថម្ភដោយគណៈកម្មការជាតិត្រួតពិនិត្យគ្រឿងញៀនចិន (NNCC) តាមរយៈអង្គការ UNODC និង សម្ភារៈគម្រោង PATROL ។

៥.៩. ត្រៀមចូលរួមសន្និសីទស្តីពី ការត្រួតពិនិត្យសារធាតុគីមីផ្សំ នៅតំបន់អាស៊ី ដែលនឹងត្រូវប្រារព្ធនៅប្រទេសថៃ នា ខែកញ្ញា ឆ្នាំ២០១៣ ។

ក្រៅពីទិសដៅការងារខាងលើ  អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត  ដើម្បីបំពេញឱ្យយុទ្ធសាស្រ្តជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានដូចជា :

- រៀបចំដំណើរការផ្សព្វផ្សាយជាផ្លូវការនូវទិន្នន័យនៃការប៉ាន់ប្រមាណពីចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ។
- បន្តការពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ  ស្តីពីការរៀបចំ  និងការប្រព្រឹត្តទៅនៃមូលនិធិរបស់អាជ្ញាធរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ធ្វើបច្ចុប្បន្នភាព "គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន" ឆ្នាំ២០១៣ ។
- បន្តត្រួតពិនិត្យការអនុវត្តផែនការជាតិ៣ឆ្នាំ (២០១៣-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

អគ្គលេខាធិការ

ឧត្តមសេនីយ៍ឯក យូ_ស៊ុនឡុង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

"ដើម្បីជូនជ្រាប"

-ក្រសួង សមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

-ឯកសារ